ហាមលក់
កម្មសិទ្ធិរបស់រដ្ឋ

ក្រសួងអប់រំ យុវជននិងកីឡា

# ថៅកែចិត្តចោរ

ព.ស ២៥៤៥ គ.ស ២០០១

# បញ្ជីខ្ចីសៀវភៅ

សាលារៀន :

កំរងសាលារៀន :

ស្រុក / ខណ្ឌ :

ខេត្ត / ក្រុង :

ថ្ងៃ ខែ ឆ្នាំ ដែលសាលារៀនទទួលបានសៀវភៅ :

| ឈ្មោះសិស្សខ្ចីសៀវភៅ | ថ្ងៃ ខែ ឆ្នាំ ខ្ចីសៀវភៅ | សភាពលក្ខណៈ សៀវភៅ | ថ្ងៃ ខែ ឆ្នាំ សងសៀវភៅ | សភាពលក្ខណៈ សៀវភៅ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

## ចំពោះគ្រូបង្រៀន

សូមសរសេរឈ្មោះសិស្សអោយបានច្បាស់នៅក្នុងខ្ទង់ « ឈ្មោះសិស្សខ្ចីសៀវភៅ » ។

សូមប្រើអក្សរខាងក្រោមនេះ ដើម្បីបញ្ជាក់សភាពលក្ខណៈរបស់សៀវភៅ :

ក. ( សៀវភៅថ្មី )

ខ. ( សៀវភៅប្រើហើយ ដែលនៅមានសភាពល្អ )

គ. ( សៀវភៅប្រើហើយ ដែលមានសភាពមធ្យម )

ឃ. ( សៀវភៅប្រើហើយ ដែលមានសភាពអន់ រឺចាស់ )

សូមលើកទឹកចិត្តសិស្ស និងជួយសិស្សក្នុងការថែរក្សាសៀវភៅដែលបានខ្ចី ។

# ថៅកែចិត្តចោរ

ព.ស ២៥៤៥ គ.ស ២០០១

# សេចក្តីផ្តើម

គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ បានទទួលការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា អោយបោះពុម្ពសៀវភៅ " **ចៅកែចិត្តចោរ** " ឡើងវិញ ដើម្បីរក្សាការពារកេរដំណែលវប្បធម៌ អក្សរសាស្ត្រជាតិ និងបំពេញសេចក្តីត្រូវការរបស់ប្រិយមិត្តអ្នកអាន និងសិស្សានុសិស្ស ។ ក្នុងការបោះពុម្ពផ្សាយឡើងវិញនេះ យើងខ្ញុំបានរក្សាអត្ថន័យ អត្ថរស ខ្លឹមសារ និងឃ្លោងឃ្លា នៅដដែលទាំងស្រុង ។

យើងខ្ញុំរីករាយនឹងរង់ចាំទទួលនូវការរិះគន់កែលំអ ក្នុងន័យស្ថាបនាពីសំណាក់ប្រិយមិត្តអ្នកអាន និងសិស្សានុសិស្ស ដើម្បីធ្វើអោយការបោះពុម្ពផ្សាយលើកក្រោយៗ កាន់តែសុក្រឹតថែមទៀត ។

បោះពុម្ពផ្សាយឡើងវិញតាមច្បាប់ដើម

ដោយគ្រឹះស្ថានបោះពុម្ព និង ចែកផ្សាយ

នៃក្រសួងអប់រំ យុវជន និង កីឡា

១៤៨ មហាវិថីព្រះនរោត្តម ភ្នំពេញ

ចំនួន ៥ ០០០ច្បាប់

**រោងពុម្ព អប់រំ**

គ.ស. ២០០១ ព.ស. ២៥៤៥

# អារម្ភកថា

រឿង "**ចៅកែចិត្តចោរ**" ដែលបាននិពន្ធឡើងដោយលោក ញ៉ុក យូឡេង និងអ៊ុំឈឹន កាលពីឆ្នាំ១៩៥៦ បានគូសបញ្ជាក់ប្រកបដោយសិល្បៈខ្ពស់ ហើយសាមញ្ញ នូវលក្ខណៈសារវន្តមួយ នៃសង្គមខ្មែរក្នុងសម័យនោះ ។ ដើម្បីឆ្លើយតបនឹងតំរូវការសិក្សាជាបន្ទាន់ របស់សិក្សានុសិស្ស យើងលើកយករឿងនេះមកសរសេរក្នុងកុំព្យូទ័រ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់ ។ ប៉ុន្តែយើងគួរដឹងថា នៅឆ្នាំ ១៩៨០មុនយកមកសំដែងតាមសំនូមពរ លោក ញ៉ុក យូឡេង បានយកវិញត្រង់អន្លើខ្លះ ។ រឿងដែលមិត្តអ្នកសិក្សា កំពុងកាន់អាននេះ គឺជារឿងដែលអ្នកនិពន្ធបានកែលំអរួចហើយនោះឯង ។ ក្នុងការផលិតសៀវភៅរឿងនេះឡើងវិញ យើងបានរក្សាខ្លឹមសាររឿង ការកាត់កងឆាកតាមលំនាំរបស់អ្នកនិពន្ធទាំងស្រុង ប៉ុន្តែយើងគ្រាន់តែកែលំអក្ខរាវិរុទ្ធខ្លះ ដើម្បីអោយមានការឯកភាពគ្នារវាងសៀវភៅសិក្សា ។ ម្យ៉ាងទៀត ដើម្បីកុំអោយលក្ខណៈ "កាល" ពីឆ្នាំ១៩៥៦ផង យើងក៏សំរេចយកពាក្យ "រាជការ" មកប្រើជំនួសពាក្យ "រដ្ឋការ" វិញ ។ យើងត្រៀមចាំទទួលការរិះគន់ស្ថាបនា ពីមិត្តអ្នកសិក្សាគ្រប់ពេលវេលាដោយសោមនស្សរីករាយ ។

សូមថ្លែងអំណរគុណចំពោះនាយកដ្ឋានសិល្បៈ ក្រសួងឃោសនាការ និងវប្បធម៌ ដែលបានផ្តល់ឯកសាររឿង "ចៅកែចិត្តចោរ" នេះមកជាគុណប្រយោជន៍ដល់សិស្សានុសិស្ស ។

វិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រក្រសួងអប់រំ

ភ្នំពេញ, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ១៩៨៩

# តួឯក

១. នាយ ជានីត អាយុ ១៧ឆ្នាំ ធ្វើការក្នុងហាងឡាន

២. ពូ ហំ អាយុកណ្ដាលមនុស្ស តៃកុងឡាន

៣. ថៅកែឡាន

៤. នាង យ៉ាន ប្រពន្ធពូ ហំ

៥. សុខ ... កម្មករឡាន

៦. មាន ... កម្មករឡាន

៧. គង់ ... កម្មករឡាន

៨. ថ្រី ... កម្មករឡាន

៩. ពួកក្រុមនគរបាល បីនាក់

រឿងនេះប្រឌិតមានឡើងនៅទីក្រុងភ្នំពេញ

# ភាគទី ១

## ជានីត និងតៃកុង

(គេឃើញជានីតនៅក្មេងរាងស្គម កំពុងកត់ត្រា ចុះដាក់បញ្ជីសៀវភៅធំមួយ ទើបពូ ហាំ ចំណាស់ពាក់កណ្ដាលមនុស្ស ដើរចូលមកលបៗ ។ ជនទាំងពីរឃើញគ្នា សំលឹងគ្នាយូរបន្តិច ទើបពូ ហាំនិយាយ)

ពូហាំ : លោកក្មួយមានរឿងអ្វី បានមើលពូតាំងពីក្បាលដល់ចុងជើង ហាក់ដូចជាយើងមិនដែលស្គាល់គ្នា ?

ជានីត : ពូក្រែង ... ក្រែងឡានពូ ...

ហាំ : ចៅកែនៅហ្នឹងរឺទេ ?

ជានីត : ចេញបាត់តាំងពីព្រលឹមម្ល៉េះ

ហាំ : យី ! ផ្ញើរម៉ានទៅគាត់ត្រឡប់វិញពូមានរឿងប្រញាប់ជាមួយនឹងគាត់ផង ។

ជានីត : មើលទៅបន្តិចទៀតគាត់ នឹងអញ្ជើញមកវិញហើយ ។

ហាំ : ចុះពួកអាដែងអស់នោះ កំពុងតែរៀបចំ ធ្វើឡានអាជាគោរី ?

ជានីត : បាទ !

ហាំ : ទៅមើលពួកអាដែងអស់នោះ មួយភ្លែតសិន ! (ដើររួចខុចវិញ) ណ្ហើយកុំអោយវាឃើញមុខនាំពិបាកចិត្តទេ ។

ជានីត : អញ្ជើញអង្គុយទៅពូ(ពូហាំធ្វើតាម) ខ្ញុំឡើងទៅផ្ទះសិន(ជានីតក៏ដើរយ៉ាងលឿនចេញពីទីនោះ ហាក់ដូចជាខ្លាចមិនហ៊ានអង្គុយជាមួយតៃកុង) ។

ហាំ : លោកក្មួយកុំទៅណាអង្គុយនៅនេះហើយអោយបានពីរនាក់គ្រាន់បានជាគ្នា (ជានីត ក៏ត្រឡប់មកអង្គុយវិញតែធ្វើជាបើកសៀវភៅធ្វើការ) ។

តែកុងឡានជក់ខ្លះ ហួចខ្លះ ច្រៀងខ្លះ ទើបនិយាយថា :

យី ! ចំតែម្ដងហើយ ថៅកែទៅណាក៏ក្រមកម្លេះ ។ លោកក្ដួយ មានលឺនរណាគេនិយាយថាអ្វីពីខ្ញុំទេ ?

ផានីត : លឺគេនិយាយតែរឿងហ្នឹង ?

ហាំ : រឿងស្អី រឿងហ្នឹង !

ផានីត : រឿងពីម្សិលនុះណាំ ! ថាលោកបើកឡានទៅជល់ឡានអុងប៉ាងហុងលី .. ស្លាប់មនុស្សអស់ ៣នាក់ និងមានរបួសជាច្រើន ។

ហាំ : រួចដូចម្ដេចទៀត ?

ផានីត : ថាលោកពូរត់បាត់ ។ ឥលូវ ...រាជការប្រកាសអោយគេរកចាប់ខ្លួន មានទាំងផ្សាយតាមវិទ្យុផង ថាបើ នរណាឃើញរូបលោកពូអោយទៅជំរាបរាជការ ។ ចុះ ពូឯងមកធ្វើអ្វី កន្លែងនេះ តិចគិញមករកមើល ម្ដេចមិនគេចអោយបាត់ខ្លួនទៅ ។

ហាំ : (សើច) មុខតែនឹងគេចហើយ តែធ្វើម្ដេចអោយបានជួបថៅកែបើកលុយសិន ។

ផានីត : ប្រាក់ខែបន្តិចបន្តួច ពូអើយកុំស្ដាយ ។ ចាំទៅៗ តិចមានគ្រោះថ្នាក់ធំ បើលោកពូត្រូវការលុយធ្វើសាហ៊ុយខ្លះ ខ្ញុំជូនខ្លះបាន (ផានីតហូតកាបូបចង់រាប់លុយអោយតៃកុងខ្លះ) ។

ហាំ : (រាដៃមិនព្រមទទួលលុយ) ទុកចាយចុះលោកក្ដួយ ពូមានហើយ ។ លោកក្ដួយឯងមុននឹងមកធ្វើការនៅទីនេះ នៅឯណាពីមុន ?

ផានីត : នៅរៀនវិទ្យាល័យស៊ីសុវត្ថិ ។ ខ្ញុំ បានខំណាស់ដែរ តែប្រលងចេះតែធ្លាក់ ឥលូវមិនចង់ត្រឡប់ទៅស្រុកសោះ ព្រោះខ្មាសគេក៏មកសុំធ្វើការនៅនេះ យកលុយរៀនឈ្នួលយប់ៗទៀត ។

ហាំ : ក្មួយឯងអាយុប៉ុន្មានហើយ ?

ផានីត : ចូលឆ្នាំថ្មីនេះទៀត បាន ១៧ហើយ ។

ហាំ : នៅក្មេងណាស់ គ្មានទាន់បានដឹងរឿងកន្លុកកន្លៀតជីវិតបន្តិចសោះ ។ ពូមកនេះមកបើកលុយរង្វាន់មិនមែនមកបើកប្រាក់ខែទេ ប្រាក់ខែបើកចាយអស់ ១ខែមុនស្រេចទៅហើយ ។

ផានីត : រង្វាន់ដោយពូបានធ្វើការយូរណាស់មកហើយឬ ? ខ្ញុំបើធ្វើការយូរៗ ទៅ ថៅកែថា នឹងអោយរង្វាន់ខ្ញុំដែរ គឺប្រាក់ចំណេញ ដែលត្រូវចែកគ្នា តាមភាគៗនោះឬ !

ហាំ : រង្វាន់នោះ លឺគ្រាន់តែនិយាយ តែគេមិនដែលចែកទេ ។ រង្វាន់ពូគឺរង្វាន់ក្តៅៗ ។ គឺថៅកែណាំ ដែលជាអ្នកបញ្ចេះអោយពូបុកឡាន អាហ៊ុងលីអោយ វាមានគ្រោះថ្នាក់ គេលែងហ៊ានជិះទៀត គេមកជិះតែឡានយើង ហើយថៅកែសន្យាថា បើពូធ្វើបានគាត់អោយរង្វាន់ ១ម៉ឺនរៀល។ រឿងនេះ ជារឿងស្ងាត់កុំនិយាយអោយសោះ ។

ផានីត : យី ! អូអញ្ចឹងម្សិលមិញ គឺពូបុកឡានវាដោយចេតនាតែម្តង ។

ហាំ : នឹងហើយ ! ដាក់អាមួយម៉ោងមួយរយ ទាន់អាឯងព្រលែងចំកណ្តាលស្ពឹងជំនីរ ។

ផានីត : យី ! ពូហ៊ានធ្វើអញ្ចឹង !

ហាំ : មិនហ៊ានឯណា "មួយម៉ឺនរៀល"... ។

ផានីត : ចុះមានអ្នកជិះបានស្លាប់ ដោយពូឯងបុកឡាននោះ ។

ហាំ : ពួកនោះវាស៊យវា អាយុវាអស់។ អ្នកណាដឹងធ្វើម៉េច ។

ផានីត : ចុះឥលូវបើរាជការគេមករកចាប់ពូឯង ?

ហាំ : អោយតែបានមួយម៉ឺនគេចប្រាវឥលូវ ។ យូរៗភ្លេចខ្លួនបន្លំផ្លាស់ឈ្មោះ

មកវិញដដែល ។ ហើយម្យ៉ាងទៀតថៅកែ គាត់សន្យាថា គាត់ជួយគិតគូរ គេឯង ។ រឿងអ្វីតែមានលុយហើយ វាមិនដែលទៅជាធំរួចទេ ។

ផានីត : ខ្ញុំ បើថៅកែប្រើបែបនេះ ទុកជាអោយលុយយ៉ាងណា ក៏មិនហ៊ានដែរ ។

ហាំ : ចុះបើក្មួយធ្វើការរាជការ និយាយអោយត្រង់ណាំ ! តើលោកក្មួយហ៊ានស៊ីសំនូកឬទេ ? និយាយអោយត្រង់ណាំ !

ផានីត : ខ្ញុំ មិនហ៊ានថាទេ ។

ហាំ : ឃើញទេរឿងស៊ីសំនូក និងរឿងបែបពូនេះ មិនខុសគ្នាប៉ុន្មានទេ ។

ផានីត : ពូឯងសំលាប់គេទាំងរស់ណា ។

ហាំ : ចុះស៊ីសំនូកមិនកាច់កគេទាំងរស់ ! ចុះបំបាត់លុយរាជការ មិនកាច់កគេទាំងរស់ ! អ្នករកស៊ី បំបាត់គេគ្រប់យ៉ាង មិនកាច់កគេទាំងរស់ !

ផានីត : ឱពុទ្ធោអើយ ! ខ្ញុំ យ៉ាងណាក៏មិនហ៊ានដែរ ទុកជាគេអោយប៉ុន្មាន ក៏មិនហ៊ានសំលាប់មនុស្សដែរ ។

ហាំ : កុំអាលរកពុទ្ធោ ! បើមិនសំលាប់គេមានតែទុកអោយគ្នាឯងស្លាប់ ! ក្មួយរើសមើល៍យកខាងណា ?

ផានីត : ខ្ញុំ មិនយល់ទេពូ ពូឯងចង់ថាដូចម្ដេច អំបាញ់មិញ ?

ហាំ : ថា “បើមិនដាច់ចិត្តសំលាប់គេតោងគ្នាឯងស្លាប់” តើគ្នាឯងស្លាប់ ក្មួយឯងធ្វើដូចម្ដេច ?

ផានីត : ម៉េចអញ្ចឹង ?

ហាំ : ពូត្រូវការលុយមួយម៉ឺន គ្មានមួយម៉ឺន ប្រពន្ធពូងាប់ ឈើដើមទ្រូងក្អកខេះៗ ត្រូវការសំរាកមិនធ្វើការ តើបានអ្វីស៊ី ។ ទៅពេទ្យៗ អោយសំបុត្រទិញថ្នាំចាក់ ។ ពូគ្មានលុយទិញថ្នាំធ្វើម្ដេចទុកអោយប្រពន្ធស្លាប់ឬ ? កូនស្រីពូប្រលងជាប់ចូលអនុវិទ្យាល័យនារី សាលាតំរូវអោយទិញសំពត់

អាវ សៀវភៅ មុងតាមរបៀបគេ មិនទិញអោយកូន កូនខាតរៀន ។ ខាតរៀនល្ងង់ដូចពូទៀត ។ ធំឡើងវេទនា ម្ល៉ោះហើយ ត្រូវពូ ហ៊ានប្តូរ អោយកូនបានចំណេះនិងគេ ទើបដោះបញ្ហានេះអោយបានស្រេចខំវិល វល់តែដដែលៗនៅតែល្ងង់ ព្រោះហេតុក្រនៅតែក្រ ព្រោះហេតុល្ងង់ ...ម្ល៉ោះហើយប្រថុយធ្វើម្តេចអោយតែបានលុយ និងបានចំណេះទៅ ។ ម្តាយ ពូគាត់ចាស់ហើយ ហើយគាត់ចង់ធ្វើបុណ្យមុននឹងគាត់អនិច្ចកម្ម គាត់សុំលុយពូអោយពូធ្វើម្តេច មិនអោយគាត់ធ្វើបុណ្យធ្វើទាន ហាក់ដូច ជាធ្វើទណ្ឌកម្ម សំរាប់គាត់អញ្ចឹង ...

ផានីត : ពួយកលុយក្តៅក្រហាយទៅជូនគាត់ យកទៅធ្វើបុណ្យ ក្រែងមិនបាន បុណ្យណាំ ?

ហាំ : បាន ឬ មិនបានទុកមួយឡែកសិន ធ្វើម្តេចអោយតែម៉ែបានស្រួលចិត្ត ដោយថាអញមានលុយធ្វើបុណ្យនឹងគេដែរ ស្រុកឥលូវអញ្ចឹង គេកាប់ ជ្រូកធ្វើបុណ្យ គេស៊ីសំនួកធ្វើបុណ្យ ឬ គេធ្វើបុណ្យដើម្បីមានផ្លូវរកស៊ី គេសំពះព្រះសង្ឃ ដើម្បីអោយគេស្រឡាញ់(ផានីតគ្រវីក្បាល ហួសចិត្ត) លោកក្អួយគ្រវីក្បាលហួសចិត្ត ! នេះហើយជីវិតពិតៗ ដែលមិនមែន ជីវិតតែពាក្យសំដី តែក្បួនខ្នាតបានថា សរុបសេចក្តីឃើញថា ពូត្រូវតែ ប្រថុយអោយបានមួយម៉ឺនរៀលសិន ។ ពូគិតស្រេចយូរណាស់មក ហើយ ពូល្បងស្រាយរឿងនេះតាមវិធីច្រើនណាស់ហើយ តែទៅមិនរួច បានជាសល់តែផ្លូវមួយហ្នឹង ទើបប្រថុយទទួលថៅកែ គាត់ត្រូវការស្រាប់ ផង ចាំអី និងលេងមួយចាន ដើម្បីកសាងជីវិតវង្សត្រកូល ។

ផានីត : ខ្ញុំឈប់ឮ ឈប់ឆ្លើយ ឈប់ដឹងហើយ ! (ដើរចូលមកអង្គុយ)

ហាំ : កើតមកជាមនុស្សហើយ ក្អួយមិនអោយឈប់ឮ ឈប់ឆ្លើយ ឈប់ដឹង បានទេ ! ច្បាប់ជីវិតបង្ខំក្អួយអោយដោះស្រាយ រឿងដែលមានចោទ

រាល់ៗថ្ងៃ ។ បើក្មួយគេចមិនដោះស្រាយ គឺក្មួយព្រមទទួទងាប់ជាមុន ហើយស្រេច ។

ផានីត : ខ្ញុំនឹកថា ខ្ញុំហើយជាមនុស្សអភ័ព្វជាងគេ កំព្រាឥតឪពុកម្ដាយ នៅជាមួយមាមីង គេអ្នកមាន គេធ្វើបាបគ្រប់យ៉ាងរកតែរៀនដោយចិត្តស្ងប់មិនបាន ។ គេប្រើឆ្វេងប្រើស្ដាំ ជ្ដាប់យ៉ាងដូចម្ដេចក៏មិនត្រូវ ខ្មោចចេញខ្មោចចូល និយាយតែពីមាន ពីសប្បាយផ្ទុយនឹងខ្ញុំ ដែលក្រ ។

ហំ : មានមនុស្សវេទនាជាងក្មួយ ជាងមា ច្រើនណាស់ទៅទៀត លោកក្មួយ ។ មានមនុស្សច្រើន បានព្រឹកខ្វះល្ងាច គ្មានអ្វីវិណ្ណ គ្មានដំបូលជ្រករស់ដោយសារលក់កំលាំងប្រចាំថ្ងៃ ឈោតែឈឺ ដេកចាំងាប់ ។ ជនទាំងនោះគេប្រៀបបានទៅនឹង សត្វដែលកើតមក គេទុកអោយរស់គ្រាន់តែសំរាប់ធ្វើការផ្ដល់ផលអោយទៅជនមួយជំពូកទៀត ដែលកើតមកចាំតែទទួលផលស្រាប់ដោយមិនចាំបាច់ធ្វើការ ឬដោយធ្វើការតែបន្តិៗ ។ មួយថ្ងៃគិតតែប្រើស្មៀតបោករាប់មិនអស់ ។

ផានីត : នេះហើយសង្គមសក្តិភូមិ គ្មានរបៀបបណ្ដោយមនុស្សប្រយុទ្ធគ្នាតាមចិត្តប្រកាប់ប្រចាក់គ្នា បោកបន្លំគ្នា លួចប្លន់គ្នា កេងប្រវ័ញ្ចគ្នា រហូតដល់ច្បាំងគ្នា ដើម្បីតែម្យ៉ាងគឺ ដើម្បរស់ទៅតាមសេចក្ដីលោភ មិនចេះឆ្អែត ។ នេះហើយសង្គមពុករលួយ ដែលអ្នកប្រសប់ ចេះតែសប្បាយនៅចំពោះមុខមនុស្សភាគច្រើន ដែលវេទនា ពីរឿងរស់ ។ នេះហើយសង្គមនាយខុនមនុស្សជិះជាន់មនុស្ស ព្រោះពួកឈ្មួញចេះរៀបចំគ្នា ដើម្បីសង្កត់ពួកអ្នកចាញ់អោយធ្វើការ បង្កើតផលអោយខ្លួនរស់បានស្រួល ។

ហំ : ក្មួយបានរៀន ក្មួយចេះរកពាក្យចំៗថាបាន ។

ផានីត : ពួងងហ្នឹងក៏សំលាប់គេដើម្បីខ្លួនរស់ដែរ ។

ហាំ : ពូមានចង់ឯណាក្អួយ តែជីវិតវាបង្ខំពូទេតើ ! ដូចពូបានជំរាបក្អួយរួចមក ហើយស្រាប់ ។

ផានីត : ថៅកែ ហ្នឹងបង្ខំពូឯង ។

ហាំ : ថាដូចនេះក៏បាន ។ តែចុះនរណាបង្ខំថៅកែ ?

ផានីត : អ្នកណា ! លោភចង់មានតែឯងហួសពេក ។

ហាំ : ត្រូវហើយថៅកែ គាត់ហ៊ានលោភ ព្រោះគ្មានច្បាប់ណាមក កំរិតសេចក្តីលោភ គាត់សោះ ។ ដល់ចង់មានបានហួសកំលាំងគាត់ គាត់យកទឹកលុយទៅទិញកំលាំងគេ ហើយដោយសារកំលាំងគេ សម្បត្តិគាត់កើនឡើងៗ យូរៗទៅគាត់ទិញ ខ្មែរទាំងអស់មកប្រើ ។

ផានីត : ពិតមែនហើយ ចុះផ្លូវដោះស្រាយ ?

ហាំ : កុំមាត់លឺសូរសំលេងអា "មែរសីដេស" ថៅកែមកហើយ ។ នុ៎ះថៅកែមែន លោកក្អួយ ខ្ញុំលាលោកក្អួយអោយហើយណ៎ា ព្រោះតែបានលុយមួយម៉ឺនប្រាយគ្នឹងហើយខ្ញុំ ។

ផានីត : ចុះ ខ្ញុំពូអោយទៅណា ?

ហាំ : អង្គុយបួកលេខហើយ សង្វេគរឿងសង្គមតទៅទៀតចុះ ។

ផានីត : ពូឯងពួនត្រង់នេះសិនទៅ ក្រែងថៅកែឃើញគាត់បើកឡានចេញគេចទៅណាទៀត ។

ហាំ : ក្អួយថានេះសមម្យ៉ាងដែរ (តែកុងក៏ពួនបន្តិចសិន) ។

# ឆាកទី ២

## ផានីត - ហំ - ចៅកែ

ចៅកែ : (ដើរចូលមកមើលឃើញតែផានីត ព្រោះពូហំពួនទៅហើយ) ផានីតមានមនុស្សចំលែកមកសួរអ៊ី ... អីដែរ ?

ផានីត : បាទដូចជាមិនឃើញទេ ។

ចៅកែ : អញទៅស្ទាក់ខ្ទប់ឯក្រសួងគិញហើយ តែមិនដឹងជាបានផលយ៉ាងណា ? តែនៅផ្ទះប្រយ័ត្ន មើលបើមានមនុស្សចំលែកមកសួរ ឆ្លើយថាមិនដឹងៗទៅ ។

ផានីត : បាទ !

ហំ : (ស្ទុះចេញពីកន្លែងពួនមក) ក្រាបប្រណិប័តន៍ ចៅកែ

ចៅកែ : យី ! អាហំ អាឯងឆ្កួតទេឬ ! មកធ្វើអ៊ីហ្នឹង ?

ហំ : ប្របាទ ... មក ... សុំ ... នែ ... នែ....

ចៅកែ : អាឯងមិនដឹងជាគេប្រកាស តាមវិទ្យុរកចាប់ក្បាលទេ ? រួចអាឯងមកនេះគិតសំលាប់ទាំងអស់គ្នាហះ ?

ហំ : ខ្ញុំ ដឹងថាគេរកចាប់ខ្លួនខ្ញុំហើយ បានជាខ្ញុំ ឆ្លៀត មកបើកលុយរង្វាន់រួចនឹងអាលគេច ។

ចៅកែ : យី អានេះវង្វេងខួរហើយ គិតតែរង្វាន់ ជាប់គុកឯណោះមិនគិតទេ ។ ទៅ ! រត់អោយបាត់ពីទីនេះទៅ !

ហំ : ចៅកែ មេត្តាអោយលុយមកសិន !

ចៅកែ : (ហូតកាបូបយកលុយ) ហ៏ ! យក ២០០ រៀល រួចទៅឯណាអោយបាត់ទៅអាចង្រៃវាយក៏

ហាំ : កាលដែលថៅកែ មានប្រសាសន៍នឹង ខ្ញុំថាអោយខ្ញុំ មួយម៉ឺន ! ទាល់តែប៉ុណ្ណឹងដែរបានខ្ញុំប្រថុយលក់ស្បែក ។

ថៅកែ : យី អានេះ ! អញមិនដឹង ! បើ២០០ មិនយកអញមិនដឹងអីទេ ទៅ ! ចេញទៅ ! ធ្វើអោយអញមានរឿងដោយសារផងឥលូវមកលំអុករក ១ម៉ឺនទៀត អាណាតាមអាឯងទាន់ ។

ហាំ : ព្រះតេជគុណ ខ្ញុំទុកជាម៉ែឪហើយ មេត្តាខ្ញុំចុះ ។ ជីវិតខ្ញុំថ្លៃតែ ១ម៉ឺនរៀលទេ ។ ម្ដេចព្រះបាទម្ចាស់មានប្រសាសន៍ឯណាទៅវិញ ។ អោយខ្ញុំភ្លាមមក ១ម៉ឺនដូចជាបោះចោល អោយសត្វលង់ទឹកទៅចុះ ។ ព្រះតេជគុណស្គាល់ចិត្តខ្ញុំស្រាប់ហើយ ស៊ូស្លាប់រស់នឹងព្រះតេជគុណយ៉ាងណាៗ ... ។

ថៅកែ : យីអានេះ និយាយច្រើនណាស់ អញថាមិនដឹងៗហើយ ។ យកឡានអញទៅបុកគេ ខូចឡានអញងាប់មនុស្ស ៣នាក់ រឿងរ៉ាវនឹងអាឯងនេះសំបើមណាស់ ប៉ោគេវាក្ដីផង ឥលូវមករឹតឯងមួយទៀត ។
ជានីត ជួយគិតមើល អានេះវាគិតជញ្ជក់ឈាមឯង អោយនៅតែស្បែកនឹងឆ្អឹងតែម្ដង ។

ហាំ : ព្រះតេជគុណជ្រាបស្រាប់ហើយ ! ខ្ញុំបរឡានបុកគេ គឺ ធ្វើតំរូវចិត្តព្រះតេជគុណ ។

ថៅកែ : អញឱ្យបុកមែនតែអញមិនមែនអោយបុកទាល់តែមានស្លាប់មនុស្សឯណា ?

ហាំ : ខ្ញុំ ក៏មិនមែនចង់អោយមានមនុស្សស្លាប់ដែរ ។ តែនរណាប៉ាន់គ្រោះថ្នាក់បាន ?

ថៅកែ : អើ ! រួចអាឯងមកទារលុយអញទៀត ?

ហាំ : ចុះថៅកែសន្យាថា បើខ្ញុំបុកឡានអាហុង-លី-បាន អោយខ្ញុំ ១ម៉ឺន ។ ខ្ញុំទារតាមតែថៅកែសន្យា ។ (កម្មករចូល) ។

ថៅកែ : អើ ! អញអោយឯងបុកកុំអោយស្លាប់ ឥលូវមានស្លាប់ រឿងវាធំអញមិនដឹងទេ ។

ហាំ : ថៅកែគ្មានបានបញ្ជាក់មុនថា កុំអោយមានស្លាប់ ឬ អោយមានទេ ។ ថៅកែគិតថាអោយតែបុកវា យកពីខាងសំបើមថាពួកយើងសៀង ជាងពួកវាប៉ុននោះ ឥលូវខ្ញុំធ្វើតាមបានហើយ រង្វាន់ដែលសន្មត់ថាអោយខ្ញុំ អោយមកឥលូវ : ១ម៉ឺនរៀល !

ថៅកែ : យី អ៊ាំ ! សំដីរឹងណាស់ហ្ន៊ំ !

ហាំ : ថៅកែ ខ្ញុំបាទត្រូវការ ១ម៉ឺនណាស់ ព្រន្ធខ្ញុំឈឺ កូនត្រូវចូលអនុវិទ្យាល័យ ម្ដាយខ្ញុំ ចង់ធ្វើបុណ្យបន្តិចបន្តួចនឹងគេ ។ អោយតែបាន ១ម៉ឺនមកខ្ញុំយកទៅអោយប្រពន្ធកូន ម្ដាយសប្បាយខ្ញុំយ៉ាងណា យ៉ាងនោះចុះ ខ្ញុំឥតគិតទេ ខ្ញុំសូមលើកដៃសំពះថៅកែម្ដង បើមិនអាណិតខ្ញុំទេ អាណិតតែប្រពន្ធកូន ម្ដាយខ្ញុំចុះ កុំតែមានវង្សត្រកូល ខ្ញុំមិនត្រូវការ ១ម៉ឺនធ្វើអ្វីទេ ។

ថៅកែ : ឃើញទេអានេះ មានត្រង់នឹងឯងឯណា វាធ្វើការអោយឯងមិនមែនដោយស្រឡាញ់ឯងទេ តែវាធ្វើការអោយឯងដើម្បីសំរេចប្រយោជន៍ វាឯងនោះ ឯងមិនទាំងអាណិតអញផង ចុះអោយអញអាណិតឯងម្ដេចបាន ។

ហាំ : ឥលូវឈប់និយាយ ពីអាណិតខ្ញុំចុះ និយាយពីពាក្យដែលថៅកែ ដែលបានសន្យានឹងខ្ញុំ ។ ថៅកែបានថា “អាហាំអាឯងមើលស្រឿឡានអាហុង-លីអោយចំឆ្អឹងជំនីរ អញអោយឯង ១ម៉ឺនរៀល” ។ ខ្ញុំបានបញ្ជាក់ថៅកែពីរ បីដងថៅកែថាអោយ ១ម៉ឺនមែន អោយតែខ្ញុំធ្វើបាន ។

ថៅកែ : អញមិនដឹង អញមិនដែលនិយាយដូចនេះទេ អាឯង ចង់ទៅប្ដឹងៗទៅ អាឯងនិយាយអោយបែកមេឃ ក៏គ្មានលោកណាជឿឯងដែរ ។ នាម៉ឺនគេជឿអញអាសំអុយ ។

ហាំ : ថៅកែមិនខ្លាចឆ្កែទាល់ច្រកទេឬ ? លេងបញ្ចុះអោយប្ដឹងតិចខ្ញុំប្ដឹងមែន ខ្ញុំមានសាក្សី ខ្ញុំណាំ ព្រោះកាលថៅកែនិយាយគឺថៅកែ និយាយនៅចំពោះមុខអាដែងអស់នោះ អាសុខ អាមាន អាទ្រី អាគង់ សុទ្ធតែបានឮពួកទាំងនោះ វាទាំងបានឃាត់ខ្ញុំ កុំអោយធ្វើផង ។

ថៅកែ : (សើច) ពួកអាអស់នោះ វាមិនមែនឆ្កួត ទៅសំលាប់អញអោយអាឯងរស់នោះទេ ។ ទុកជាវាលឺមែន អោយលុយវាខ្លះទៅ វាទៅជាមិនឮវិញហើយ ។

ហាំ : កុំអាងទឹកប្រាក់ ហើយមើលងាយមនុស្សពេក ថៅកែ !

ថៅកែ : កុំអាងទឹកចិត្តមនុស្សធម៌ ហើយមើលងាយកំលាំងប្រាក់អាហាំ !

ហាំ : អ្នកមានស្គាល់តែពីលុយ តែម្ដង គ្មានចិត្តមេត្តា គ្មានសម្បជញ្ញៈទេ ។

ថៅកែ : បើអ្នកក្រមិនស្គាល់លុយ អ្នកក្រមកទារ ១ម៉ឺនធ្វើអ្វី ? ។

ហាំ : ព្រោះអ្នកក្រត្រូវការលុយយកមកចិញ្ចឹមជីវិត ខុសពីអ្នកមានដែរ ត្រូវការលុយសំរាប់យកទៅ អួតប្រាប់គេថា ខ្លួនមានលុយច្រើន ឬ សំរាប់ជាគ្រឿងបញ្ឆោតចិត្ត អោយសប្បាយរីកថ្លើមធំជាន់គេ ជាន់ឯង ។

ថៅកែ : យីអានេះ កាន់តែព្រហើនឡើងៗ ចេញពីផ្ទះអញអោយឆាប់ ។

ហាំ : ជានីតជាសាក្សីខ្ញុំមួយទៀត ថាថៅកែបានប្រើអោយខ្ញុំ បុកឡានអាហុង-លីមែនថា អោយខ្ញុំ ១ម៉ឺន ឥលូវមិនអោយ ។ យើងនិយាយគ្នាទាំងប៉ុន្មានជានីត បានស្ដាប់ឮទាំងអស់ ។

ថៅកែ : ចេញពីផ្ទះអញទៅ !

ហាំ : អោយ ១ម៉ឺនមក !

ថៅកែ : ទៅ !

ហាំ : ទេ ។

ថៅកែ : អាហាំទៅ អាណិតអញហ៏ ! អញអោយ ៥០០៖០០ ។

ហាំ : ថៅកែអាណិតខ្ញុំ អោយខ្ញុំ ១ម៉ឺនមក ។

ថៅកែ : ១ម៉ឺន ! ១ម៉ឺន ! អញបានពីណាមក ?

ហាំ : បានពីខ្ញុំ ពីផានីត ពីអាសុខ ពីអាទ្រី ពីអាមាន អាគង់ ពីខ្មែរអ្នកធ្វើការទាំងអស់គ្នា ។

ថៅកែ : អាហាំចេញពីផ្ទះអញអោយឆាប់ក្រែងលោ ...

ហាំ : ក្រែងលោស្អី ខ្លាំងណាស់ ចូលគុណទាំងអស់គ្នា ។ រឿងបុកឡាន ខ្ញុំគ្រាន់តែជាដៃជើង ខួរក្បាលគឺថៅកែឯង ។

ថៅកែ : អាហាំ ... អាហាំ ... អាហាំ ... អញអង្វរអាឯង ។

ហាំ : អង្វរខ្ញុំធ្វើអ្វី ឋានៈថៅកែ មិនត្រូវអង្វរខ្ញុំទេ ខូចកិត្តិយស អ្នកមានអស់ហើយ ។ ម្យ៉ាងទៀត ខ្ញុំលែងឆោតហើយ សំលេងទន់របស់ថៅកែ គ្មានឥទ្ធិពលមកលើខ្ញុំទៀតទេ ។ លុយ១ម៉ឺនដែលសន្យា ទើបលួងចិត្តខ្ញុំបាន ។

ថៅកែ : អាហាំឯងចង់សំលាប់អញឬ ? បានជាអញនិយាយអ្វី ឯងធ្វើដូចជាថ្លង់ដូចជាស្តាប់គ្នាពុំបាន ! ខំជួយឯងពីនោះ មកឥតប្រយោជន៍សោះ ផ្គត់ផ្គង់តាំងពីខោអាវ លុយស៊ីបខ្លះទៀត កូនប្រពន្ធឯង ក៏អញមិនធ្មេចភ្នែកដែរ ។ តាំងពីនោះមក យើងមានរឿងសុខទុក្ខជាមួយគ្នាច្រើន ៖ អញ ពឹងអាឯងក៏មាន ឯងពឹងអញក៏មាន ម្តេចឥលូវម៉េចនិយាយគ្នាស្តាប់ពុំបាន ។ អញអស់ប៉ុននឹងហើយ ! មើលនាយផានីត ឯណេះគ្មានការធ្វើ អញយកមកឱ្យធ្វើការជាមួយ អញជួយយុវជន ។ រឿងអ្វី ដែលរាជការ

ហៅអោយជួយជាតិ អញមិនដែលខានទេ តាំងពីសង់សាលា ទិញឆ្នោត វត្តជួយសមាគម សង់សាលាបាលី សង់វត្ត ធ្វើបុណ្យ ទានគ្រប់សព្វ នៅតែមិនដឹងអញទៀត ។ អញសព្វថ្ងៃខ្សោះអស់ហើយ គេជញ្ជក់គ្រប់ទិស នៅតែស្បែក និងឆ្អឹងទេ ។

ហាំ : ឌឺ ! រឿងថៅកែកំសត់មែន គួរសរសេរជាសៀវភៅទុកដើម្បី បញ្ជាក់ថា ថៅកែជួយជាតិសាសនាយ៉ាងណាខ្លះ ។ ថៅកែនេះជួយខ្ញុំ ជួយក្មួយឯណោះដើម្បីប្រើយកកំរៃពីខ្ញុំ នឹងពីក្មួយឯណោះ ។ ជួយជាតិយក ចំណេញពីជាតិ ។ ជួយសាសនាយកចំណេញពីសាសនា ។ គោរពសរសើរពីស្តេច ដើម្បីយកចំណេញពីស្តេច កុំត្រដាងអំពើល្អប្រាប់យើងខ្ញុំ នោះទៅមិនរួចទេ ថៅកែ និងខ្ញុំមានរឿងតែយ៉ាងខ្លីជាមួយគ្នាអោយខ្ញុំ ១ម៉ឺន ដូចសន្យា ឬមិនអោយ ? បើអោយខ្ញុំ ខ្ញុំមិនឆ្លើយដាក់ថៅកែ ខ្ញុំសុខចិត្តធ្មេចភ្នែក ជួយថៅកែទៀតចុះ ។ បើមិនអោយទេ...ខ្ញុំសូមទោស ឆ្លើយដាក់ហើយ ។

ថៅកែ : ផានីត បើមាននរណារកអញ ថាអញទៅជួបនឹងគេ ថាមិនដឹងជាធ្វើរម៉ានបានមកវិញទេ ។

ហាំ : ថៅកែគិតទៅណាហ្នឹង ? អញ្ជើញទៅណាមិនបានទេ ។

ថៅកែ : អាឯងស្អី ក៏មកផ្តាច់សិទ្ធិអញមិនអោយទៅណាបាន ?

ហាំ : មានរឿងមួយវាភ្ជាប់ ថៅកែនឹងខ្ញុំ

ថៅកែ : អញទៅ !

ហាំ : ខ្ញុំ មិនអោយទៅ !

ថៅកែ : អញនៅតែទៅ ។

ហាំ : ទៅខ្ញុំទៅតាម ។

ថៅកែ : អញឡើងឡាន ។

ហាំ : ខ្ញុំឡើងដែរ ។

ថៅកែ : អញទៅប្ដឹង ។

ហាំ : ហ៊ានទៅប្ដឹងល្អហើយ ។

ថៅកែ : អញទៅហើយ ។

ហាំ : ខ្ញុំទៅតាមដែរ ។

# ឆាកទី ៣

## ជានីត - កម្មករ - សុខ - មាន - ទ្រី - គង់

(ដោយថៅកែ និងតៃកុង ហាំចេញពីទីនោះទៅ ពួកកម្មករធ្វើឡានដោយមានលឺជជែកគ្នាយ៉ាងខ្លាំង នាំគ្នាមកសួរមើល តើមាននរណា មានរឿងអ្វី)

ទ្រី : លោកប្អូនមានរឿងអ្វី លឺមាត់នរណាជជែកគ្នាខ្លាំងម្ល៉េះ ?

ជានីត : (ងើបមុខឡើង រួចអោនទៅវិញ)

សុខ : បើសួរគេមិនឆ្លើយជជែល មកទៅធ្វើការយើងវិញ ។

គង់ : ទេចង់ដឹង ។ នែ លោកប្អូននរណាមានរឿងអ្វី ?

ជានីត : រឿងធំណាស់ ខ្ញុំមិនហ៊ាននិយាយជំរាបទេ ។

មាន : យី ! យ៉ាងណាទៅមិនស្រួលទេដឹង ?

ទ្រី : ប្រាប់យើងអោយដឹងផងមើល៍ ។

ជានីត : នែ ! ...នែ ... ពូហាំគាត់មកហើយ គាត់ជាប់ឈ្លោះនឹងថៅកែ ពីរឿង ...ណេ្ហីយ កុំសួរខ្ញុំ ខ្ញុំនិយាយមិនរួចទេលោកអើយ ! ក្នុងលោកនេះ បើខ្ញុំកើតមកហើយកុំអោយមានភ្នែកមានត្រចៀកប្រហែលជាខ្ញុំបានសប្បាយជាង ។ ខ្វាក់ ថ្លង់ គ កុំអោយឃើញលឺ និយាយចេញ ឮរឿងតែម្តងទៅវាធូរដើមទ្រូងជាង ! ខ្វាក់ត្រង់ជាអាការៈ អាចនាំអោយមនុស្សពិបាកខ្លះមែន តែពិបាកនោះ តូចជាងអាការៈ ឃើញលឺ ចេះនិយាយ ហើយធ្វើអ្វីមិនកើត ។ មនុស្សយើងរស់សព្វថ្ងៃប្រយុទ្ធគ្នា ក្នុងអយុត្តិធម៌ លួចល្បិចគ្នាទៅវិញទៅមក ដើម្បីម្នាក់ៗបានស្រួល ល្អពីរោះតែសំដីក្រៅ តែមេខន្មេញចាំមាត់ សំរាប់បង្រៀនសិស្សានុសិស្ស អោយគ្នាសូត្រមួយថ្ងៃៗអំពីសេចក្តីល្អទៀងត្រង់សម្បជញ្ញៈ ករណីយកិច្ច ចិត្តមេត្តា ចិត្តបរិសុទ្ធ ចិត្ត

មនុស្សធម៌ តែក្នុងជីវិត ក្នុងសង្គម រឿងល្អទាំងអស់អំបាញ់មិញ ដែលបានរៀនចេះពីសាលាមក ហើយយកមកប្រើស្ទើរតែមិនកើត ក្នុងជីវិតនេះ ។

គង់ : លោកប្អូនកុំអាលផ្ទុះភ្លាម អញ្ជើញនិយាយប្រាប់យើងអោយស្រួលមករឿងយ៉ាងម៉េច ?

ផានីត : រឿងឡានបុកពីម្សិល !

សុខ : ណ្ហើយគិតអោយសព្វៗទៅ មិនត្រូវយើងចង់ដឹងរឿងគេទេ ។ មកទៅធ្វើការវិញពួកយើង ។

គង់ : រឿងនេះវាទាក់ទងដល់យើងទាំងអស់គ្នា សុខត្រូវតែយើងចង់ដឹងបានត្រូវ ។

ផានីត : បងទាំងអស់សួរខ្ញុំថា រឿងបុកឡានរួចវាម្តេច ទៅចុះក្រែងដឹងស្រាប់ហើយរឿងលុយ ១ម៉ឺន ។

មាន : អើ ... អើ ... អើ ...

ផានីត : ឥលូវស្ងាត់តូចទៅហើយ ថៅកែថាគាត់ មិនដឹងទេ ។

ទ្រី : ពួកអានាយទុនទុកចិត្តមិនបានទេ ដូចត្រីឆ្តោរអញ្ចឹង ដើម្បីវាធំធាត់ វាគ្មានញញើត និងស៊ីកូនឯងឡើយ ។

សុខ : លោកបងហាំ គាត់មិនជឿខ្ញុំៗ និយាយប្រាប់ថាអោយប្រយ័ត្ន តិចលោថៅកែ មិនទទួលដឹងយើងងាប់តែម្តង ។

ផានីត : ឥលូវ ពូ ហាំឡាំប៉ា អោយខាងតែបាន ។

សុខ : អា ! លេងមិនកើតទេដូចនេះ រឿងនេះធំណាស់ !

មាន : មកទៅធ្វើការវិញ តិចលោវាលដាលដល់យើង រឿងនេះអញច្បាស់ជាមិនយកដំរពៀមកត្បៀតក្លៀកទេ ។ អញស្រេចតែមិនដឹងៗ រួចគ្នាតែប៉ុន

នឹងហើយ ។ នុ៎ះ លីសួរដូចជាថៅកែមកវិញហើយ មកទៅធ្វើការវិញពួកយើង ។

ទ្រី : លោកប្អូនមើលផងណា៎ លោកបងហាំតែហួសចិត្តគាត់ៗព្រលែងឥតស្គាល់ថៅកែថៅកំអ្វីទេ ។

តង់ : បើមាន រឿងមិនស្រួល មើលទៅហៅពួកយើងផង ។ ទាំងអស់គ្នាត្រឡប់ទៅធ្វើការវិញទៅ ។

# ឆាកទី ៤

## ផានីត - ថៅកែ និង តៃកុង

ថៅកែ : អញថាម៉ាត់ណា ម៉ាត់ហ្នឹងហើយ ។ អាហាំតិចលោថាអញមិនប្រាប់ ។ តែគេចាប់អញៗឆ្លើយថា អញមិនដឹងអ្វីទេ ហើយអញត្រូវតែចេញឈ្មោះប្ដីងអាឯងទៀតផង ដោយចោទថាអាឯងធ្វើការខ្ជីខ្ជា បើកឡានអញទៅបុកឡាន អុងប៉ាង ហុងលី ។

ហាំ : ខ្ញុំសូមអរគុណថៅកែហើយៗ ដើម្បីតបគុណនេះ ខ្ញុំសូមជំរាបថៅកែជាមុនវិញថា តែគេចាប់ខ្ញុំ ខ្ញុំឆ្លើយប្រាប់រាជការ នូវរឿងពិតហើយ គឺថៅកែបានប្រើខ្ញុំអោយធ្វើអំពើដ៏លាមកនោះមែន ដោយសន្យាថាអោយខ្ញុំ ១ម៉ឺនរៀល ។

ផានីត : សូមទោស ... ថៅកែ ១ម៉ឺនរៀល ល្មមអោយទៅពូហាំដែរ ដូចជាធ្វើទានអោយប្រពន្ធកូនម្ដាយ ឪពុកគាត់ចុះ ។

ថៅកែ : (គំហក) ខ្ញុំនិយាយឯងដឹងរឿងអ្វីដែរ គិតតែកាន់បញ្ជីអោយត្រឹមត្រូវទៅមិនគិតទេ ។ អញទៅជួបគេបន្ដិច ថៅកែធ្វើជាដើរចេញទៅ ពូហាំចង់ដើរចេញទៅតាម ឃើញដូចនេះ ថៅកែ ក៏ចូលមកវិញ ពុទ្ធោ ! ពុទ្ធោ ! គ្មានឈ្លើងឯណាមកទាមខ្ញុំទេ អោយជាប់ជាងឈ្លើងមនុស្សទេ ។

ហាំ : មិនដឹងនរណាជាឈ្លើង នរណាទេ ថៅកែជាឈ្លើង គួលី ឬ គួលីជាឈ្លើងថៅកែ ?

# ភាគទី ៥

## មនុស្សដដែលថែមនាងយ៉ាន (ប្រពន្ធពូហាំ) ចូលមក

នាងយ៉ាន : (ដើរចូលមកដោយយំបណ្តើរ ចូលមកឃើញថៅកែមុន មិនទាន់ឃើញប្តីនាងទេ) ឱ ! ព្រះតេជគុណម្ចាស់អើយ ! ជួយខ្ញុំផងចុះ រឿអ្វីបានជាបាត់ប្តី ខ្ញុំមិនឃើញមកផ្ទះ ហើយស្រាប់តែមានលឺពួកគិញមកព័ទ្ធផ្ទះខ្ញុំ (យំ) ។

ថៅកែ : ឃើញទេអាហាំ អញនិយាយអាឯងមិនជឿ(នាងយ៉ានក៏ឃើញប្តីខ្លួន)

យ៉ាន : យី ! ពុកវា ! តើមានរឿងអ្វី ប្រាប់ខ្ញុំអោយដឹងផង ។

ហាំ : តើពួកគិញ គេមកធ្វើដូចម្តេចខ្លះ ?

យ៉ាន : ខ្ញុំកំពុងតែ ដាត់បាយ ម៉ែគាត់ទើបនឹងមកពីវត្ត មីកាទូចកំពុងរៀបចំសៀវភៅចាស់ៗរបស់វា ស្រាប់តែមានមនុស្សពីរនាក់ចូលមកតាមទ្វារមុខ ខ្ញុំក្រឡេកមើលទៅខាងក្រៅឃើញពីរបីនាក់ទៀត ពួនជុំវិញផ្ទះព្រលឹងខ្ញុំមិនដឹងទៅឯណាទេ ស្រាប់តែលោកមួយសួរខ្ញុំថា នែ អ្នកតែកុងហាំ ទៅឯណា ? ខ្ញុំថា : លោកអើយបាត់តាំងពីព្រឹកម្សិល មិនទាន់ឃើញត្រឡប់មកផ្ទះវិញផង ខ្ញុំមិនដឹងដែរ ។ លោកទាំងនោះក៏មើលសំឡឹងចោលភ្នែកពេញខ្ទមយើង រួចលោកម្នាក់ទៀតសួរទៅម៉ែថា "លោកយាយក្រែងបានដឹងថា តែកុងហាំនៅឯណាដែរ ឬ ម៉ែ លើកដៃសំពះហើយនិយាយថា : ចាស់ទេ យកព្រះពុទ្ធធ្វើជាប្រធាន ខ្ញុំមិនបានដឹងទេ" ។ ពួកអស់លោកក៏ថយទៅវិញទៅ កាទូចលបមើលថាឃើញឡើងឡានហ្ស៊ីបទៅ ។ ពួកជិតខាងគេក៏មករោមយើងអ្វី សួរថាពួកគិញមករកចាប់អ្នកហាំហើយ ។ ឱ ! ពុទ្ធោអើយ តើឪវាឯងទៅធ្វើអ្វីនរណា ?

ថៅកែ : ខ្យ៉ានអើយ! អាហាំវាឆ្កួតហើយ វាចង់ជាប់គុក វាចង់ងាប់អញអាណិតវា អញប្រាប់វាថា អោយវាគេចខ្លួនទៅ វាមិនព្រម ។ បន្តិចទៀតពួកគិញ អូសក្បាលពីកន្លែងនេះហើយបើវានៅរឹងទទឹងអញដូចនេះ ។

យ៉ាន : ចុះរឿងអ្វី! មានរឿងអ្វីបានជាគេរកចាប់ ?

ថៅកែ : វាស្រវឹងឆ្កួត បើកឡានបុកឡានថៅកែហុងលីពីម្សិលដោយមានគ្រោះថ្នាក់ស្លាប់អ្នកជិះដល់ទៅ ៣ នាក់ ។

យ៉ាន : ឪពុកខ្មោអើយ! ដាច់ខ្យល់ស្លាប់ទៅល្អជាជាង ។ ចុះឥលូវត្រូវធ្វើដូចម្ដេច?

ថៅកែ : ធ្វើម្ដេច! ថាអោយវាគេចសិន អោយតែរួចមួយគ្រាសិនទៅ ។ អញនឹងរែកផ្លូវទៅទៀត ហើយអញក៏មិនមែនធ្មេចភ្នែកមិនមើល ខុសត្រូវលើខ្យ៉ានឯង យាយចាន់ និងកាទូចដែរ ។

យ៉ាន : ចុះឪវា បើថៅកែគាត់មានប្រសាសន៍ដូចនេះហើយ នៅចាំធ្វើស្អីទៀតក៏ស្ដាប់មិនបាន ។

ថៅកែ : អាហាំ ឥលូវប្លែកណាស់ ។

យ៉ាន : ឪវា! ខ្ញុំអង្វរថៅកែចុះ តែជាប់គុកហើយឈ្មោះយើងមិនល្អទេ ។ គេឯងជិតខាង គេធ្លាប់ស្គាល់យើងគេថា "ន៎! អ្នកហាំជាប់គុកហើយ" ។ កូនយើងដែលទៅរៀនគេថា ន៎! កូននេះឪពុកវាជាប់គុក តើអោយគ្នាយកមុខទៅទុកឯណា ? ម៉ែ បើគាត់ជ្រាបរឿងនេះហើយ គាត់នឹងព្រួយដាច់ខ្យល់មិនខាន ។ ជាប់គុកលោតែគេបណ្ដើរអោយឯង មកធ្វើការជាប់ខ្នោះដៃ ស្លៀកខៀវពាក់ខៀវ ខ្ញុំខ្មាសដាច់ខ្យល់ហើយ ។ ថៅកែគាត់និយាយយើង តោងស្ដាប់ តោងតាមគាត់ ដែលស្រឡាញ់យើង គាត់ចង់តែអោយយើងបានស្រួល ម្ដេចក៏ឪវាមិនព្រមធ្វើតាមកុំឈប់នៅស្ងៀម គិតមើលអោយមែនទែន អាណិតកើ្ដឈ្មោះកូនស្រី អាណិតម្ដាយអាណិតខ្ញុំ ។

ស៊ូអោយបែកព្រាត់ប្រាស់ កុំអោយមានលឺថាមានជាប់គុក ពូជយើង ក្រមែន តែគ្មាននរណាដែលជាប់គុកទេ ។

ថៅកែ : ហ៎ខ្យ៉ានយក ៣០០៖០០ទៅ ! ហាង ១០០ យាយចាន់ ១០០ មីកាទូច ១០០ ។

ហាំ : កុំយក ! កុំធ្វើថោក រស់ដោយសារគេដាក់ទាននោះ !

ថៅកែ : ខ្យ៉ានហាង ជួយស្តាប់មើលសំដីវា ។ រស់តាំងពីនោះមកដោយសារអ្នកណា បើមិនដោយសារអញ ? យក ៣០០ទៅខ្យ៉ាន អញធ្វើបុណ្យ ។

ហាំ : កុំ ! កុំព្រមទទួល បុណ្យពីមនុស្សបាប ។

យ៉ាន : ឪវា ឯងថាអ្វីអញ្ចេះ ថៅកែគាត់ជាអ្នកមានគុណលើយើង ។

ថៅកែ : ហាង លឺ នឹងត្រចៀកហាងស្រាប់ហើយ តិចលោថាអញបញ្ចេះណា ។

យ៉ាន : ចាស៎ ! ខ្ញុំក៏ឆ្ងល់ណាស់ដែរ ។ ចុះគេខឹងថៅកែពីរឿងអ្វី រហូតដល់ដាក់ទានលុយកាក់មិនអោយយក ? មានតែឯងខំរកលុយអោយ បានច្រើនហូរហៀរមក កុំបានព្រឹកខ្វះល្ងាច គ្មានអង្ករប្រចាំពាង គ្មានសំពត់អាវសំរាប់ផ្លាស់ ? គ្មានអ្វីជាទៀងសំរាប់ទ្រទ្រង់ជីវិតសោះ ។

ហាំ : កុំយកមកនិយាយវែងពេកទៅផ្ទះ ទៅអីទៅ !

យ៉ាន : ឪវា ! ខ្ញុំលែងយល់ឯងហើយ !

ហាំ : យល់ឬមិនយល់ ទៅផ្ទះទៅ រឿងអញស្រេចនឹងអញ ឯងកុំចេះដឹងអ្វី ។

យ៉ាន : ខ្ញុំមិនទៅទេ ។

ហាំ : នែ និយាយអោយចេះស្តាប់ ឯងមិនបានដឹងរឿងក្នុង កុំមកធ្វើជាចេះដែរ ។

យ៉ាន : អាងអ្វី អាងតែគេមិនដឹងរឿង ។ ឯងអ្នកចេះដឹង ម្តេចក៏ធ្វើអោយថៅកែពិបាកដោយសារ ?

ហាំ : មីនេះ គំនិតខ្ញុំ គេក្រាស់ណាស់ ជ្រៅណាស់ ។

យ៉ាន : (យំកាន់តែខ្លាំង) បើខ្ញុំគេ ក៏វាមិនអីដែរ កុំអោយតែជាប់គុក ។

ហាំ : យី ! មីនេះ ! (ខឹងច្រលោត)

ផានីត : ពូហាំ ! ពូហាំ ! កុំច្រលោត បើមីងគាត់ល្ងង់ កុំយកសេចក្ដីល្ងង់ទៅតប ។

ថៅកែ : អា ផានីត អាឯងចេះដឹងអ្វីដែរ ? រឿអាឯងគិតតែបូកលុយទៅ តិចអញដេញចោល អោយឈប់ធ្វើការឥលូវ ។

ផានីត : បូកលេខមិនកើតទៀតទេ ! វាច្រឡំខ្ចង់អស់ហើយ ឯងថាត្រូវ ស្រាប់តែខ្ចង់គេ ថាខុសទៅវិញ ។ ក្បួនដែលគេបង្រៀនខ្ញុំ ឯសាលាទាំងប៉ុន្មានយកមកប្រើក្នុងជីវិតនេះមិនត្រូវសោះ ។ ក្បួនប្រាប់ថាធ្វើនេះ "ល្អ" ជីវិតថា "ឆោត" ក្បួនថា "ចេះ" ជីវិតថា "ល្ងង់" ក្បួនថា "ទាប" ជីវិតថា "ខ្ពស់" ។

ថៅកែ : អាផានីត ឈប់និយាយ អញដេញអាឯងអោយឈប់ធ្វើការឥលូវហើយ ។

ផានីត : មិនចាំថៅកែដេញទាន់ទេ ខ្ញុំឈប់មុនហើយ ព្រោះច្រមុះវាមិនចៀប ខ្ញុំទ្រាំនៅជិតគំរង់ មិនបានឡើយ ។

ថៅកែ : អាផានីត ... អាផានីត ...

ផានីត : មានការអ្វីថៅកែ ?

# ភាគទី ៦

## មនុស្សដែលថៃមកម្ចករ សុខ ទ្រី មាន គង់

ថៅកែ : ចុះពួកអាអស់ទាំងនេះ ទៅណាមកណា ដើរចោលការ ? យី ! ពួកអានេះ ការនៅដៃ វាហ៊ានដើរចោលការ ។

គង់ : ពួកខ្ញុំ លឺសូរមានការ ជជែកខ្លាំងពេក ហាក់ដូចជាមានរឿងអ្វី បានជាបបួលគ្នាមកមើល ។

ថៅកែ : ទៅ ! នាំគ្នាទៅធ្វើវិញភ្លាមទៅ !

ទ្រី : បាទ ! សួរសុខទុក្ខលោកបងហាំបន្តិចសិន ។

ថៅកែ : យី ! អាឯងអស់នេះ វាឡើងចាងទាំងអស់គ្នាហើយ ! អញនិយាយអ្វីក៏គ្មាននរណាស្តាប់ដែរឥលូវ ។ បើដណ្តើមតែធំទាំងអស់ បានអ្នកណាធ្វើគូលី អ្នកណាធ្វើថៅកែ ? ឬមួយអាឯងអស់នេះ ដូចជាពួកគូលីឯទៀតៗមួយថ្ងៃៗ គ្មានធ្វើការអ្វីសោះជំនុំគ្នា តែពីគិតបះបោរ តំឡើងប្រាក់ខែ ។ អញប្រាប់ឯងមុនធ្វើជាមួយ ថៅកែណាទៀតបាន ជាមួយអញមិនបានជាដាច់ខាត ។ កើតមកជាមនុស្សក្នុងសង្គមវាតែងមានឋានៈ ខ្ពស់ទាបជាធម្មតាតាមចង្វាក់តាក់តែងមក ។ ចុះបើយើងចេះតែបះបោរចង់ស្មើមុខដូចៗគ្នា តើបាននរណាធ្វើមេ នរណាធ្វើកូន ? ស្តាប់បានទេ អាសុខអាមាន ?

សុខ : បាទ !

មាន : ព្រះបាទម្ចាស់ !

ថៅកែ : អាគង់ ! អាទ្រី !

អាគង់ : មិនយល់ មិនដឹងជាថៅកែ ចង់ថាអ្វីអំបាញ់មិញ ?

ថៅកែ : ល្មើយ ទៅ អាមនុស្សមិនយល់ នៅតែមិនយល់ដដែលនេះឯង ។
(កម្មករទាំងអស់រៀបទៅ) ។

ផានីត : កុំអាលអញ្ជើញទៅបងទាំងអស់គ្នា ។ ខាតការមួយព្រឹកចុះ ថ្ងៃនេះចាំ
ជួយស្តាប់ ជួយលឺ រឿងពូហាំផង ។

ថៅកែ : អាផានីត អាណាធ្វើអ្វីឯង ?

ផានីត : ថៅកែ ឯងហ្នឹងធ្វើខ្ញុំ ! ធ្វើអោយខ្ញុំឆ្កួតចិត្ត លើមនុស្សដែលឃើញតែពី
លុយ ពីមាន ។ រស់សព្វថ្ងៃរស់សំរាប់ តែគិតធ្វើម៉េចបើកលុយ អោយ
ហើយ ។ ក្នុងការគិតនេះគ្មានគិតល្អជាទេ គិតតែពីរកល្បិច អយុត្តិធម៌
លេងស្មៀត អាក្រក់គ្រប់យ៉ាង តាំងពីប្រើវិធីសូកប៉ាន់ វិធីកៀងមនុស្ស
អោយចូលដៃជាមួយខ្លួន រហូតដល់ធ្វើគ្រោងការសំលាប់មនុស្ស ដែល
អាចក្លាយទៅជាចំបាំងចក្រពត្តិ គ្រប់យ៉ាង ដើម្បីអោយតែបានលុយ បាន
លុយច្រើនៗជាងគេ ។

ថៅកែ : (ស្រែក) អាផានីត ! ចេញពីផ្ទះអញអោយឆាប់ !

ផានីត : ខ្ញុំចោទថៅកែ ឯងពេញទីថាជាចោរ ចោរជាន់ខ្ពស់ ព្រោះចេះបន្លំតែពិត
ជាចោរ ចោរអាក្រក់ជាងចោរឯទៀតៗផង ។ ខ្ញុំ ចោទថៅកែឯងថា ជា
មនុស្សសំលាប់មនុស្ស ដូចជាសំលាប់ បីនាក់ក្នុងកាលបុកឡានពីម្សិល ។

ថៅកែ : មិនមែនអញទេ គឺអាហាំ ។

ផានីត : មិនមែនពូហាំទេ គឺថៅកែឯង ជួលពូហាំអោយប្រព្រឹត្ត បទឧក្រិដ្ឋនោះ
ដល់ពូហាំធ្វើហើយ មិនព្រមអោយ ១ម៉ឺនរៀលទៅគាត់ទៀត ។ នេះ
ហើយសេចក្តីពិត ។ បងចូរដឹង បងមាន បងសុខ បងគង់ បងទ្រី ជួយ
ស្តាប់ ជួយលឺ ថៅកែយើងជាចិត្តចោរ ចោរប្លន់តែទាំងអស់គ្នា ។

ចៅកែ : ទេ! ទេ! អញមិនមែនចោរទេ។ ខ្សាំនជួយអញផង អាមាន អាគង់ អាសុខ អាទ្រី បើមានពួកតិញមកសួររឿងអ្វី គោងឯងជួយអញផង ចាំអញអោយលុយ។

ហាំ : នែ! មិត្តទាំងបួន! យើងជឿថា ឯងទាំងអស់គ្នាបានភ្លឺភ្នែកខ្លះហើយ ចៅកែនេះគ្មាននឹកអាណិតយើង ស្រលាញ់យើងដូចសំដី តែងនិយាយនោះទេ គិតតែពីប្រើយើង ដើម្បីយកញើសឈាមយើង ទៅពួតអោយបានជាលុយ ជួនកាលបោកយើង ដូចបានបោកអញ ជាភស្តុតាងស្រាប់។ លុះអំណាចចង់ចំណេញខ្លាំងពេក ចៅកែមិនញញើត នឹងប្រើវិធីអមនុស្សឡើយ ពួកនេះគ្មានចេះស្នេហាជាតិ ដល់តិចតួចទេ មាតុភូមិរបស់គេគឺ “លុយ” នេះឯង។

យ៉ាន : ពុទ្ធោអើយ!

ចៅកែ : អាប្អូននាក់ឯង គ្មានដឹងលឺអ្វីទេណាំ! បើគេសួរចាំអញគិតអោយម្នាក់ៗ ៥០០៛០០។

ហាំ : លុយ ៥០០៛ ចាយតែមួយភ្លែតអស់ហើយ។ ឬ សេចក្ដីយុត្តិធម៌ទៀត បើយើងយកមកដាក់ក្នុងខ្លួនបានហើយ មិនចេះសាបសូន្យទេ។ មិត្តទាំងបួន ត្រូវពិចារណាអោយមែនទែន។

ចៅកែ : សេចក្ដីយុត្តិធម៌ មានតែឈ្មោះទេ! ក្នុងលោកនេះ គ្មាននរណាប្រតិបត្តិសេចក្ដីយុត្តិធម៌បានឡើយ។ ពីព្រោះ ឬ មួយតាមការពិតគ្មាន សេចក្ដីយុត្តិធម៌ទេ ឬ មួយជនមួយពួក ចេះតែមានរបៀបយល់លើ សេចក្ដីយុត្តិធម៌ប្លែកៗគ្នា។ យុត្តិធម៌របស់ជនមួយក្រុម ខុសនឹង យុត្តិធម៌របស់ជនមួយក្រុមទៀត។ ទាំងពីរក្រុមធ្វើអំពើផ្ទុយគ្នាស្រលះ តែក្រុមមួយៗ សុទ្ធតែប្រកាសខ្លួនថា ខ្លួនធ្វើតាមសេចក្ដី យុត្តិធម៌ទាំងអស់។ ដូចនេះនៅ

ទីបំផុត មានតែ "លុយ" ទេ ដែលអាចធ្វើជាអាជ្ញាកណ្ដាល កាត់សេចក្ដីជជែក នៅលើសេចក្ដីយុត្តិធម៌ ឬ អយុត្តិធម៌។ យកលុយវិញទៅ អាប្អូននាក់ អញអោយម្នាក់ៗ មួយពាន់រៀល បើឯងឆ្លើយថា មិនបានដឹងលឺរឿងអ្វីទេ ។

ជានីត : បងទាំងប្អូន កុំអោយគេយកទឹកលុយ មកទិញទឹកចិត្តយើងបាន ។ កុំធ្វើជាមនុស្ស "សំបក" សុខចិត្តលក់គំនិតអោយគេអស់ នៅតែ "សំបក" ខ្លួនសំរាប់ធ្វើការជាអាយ៉ង ចាក់ត្លុកទៅតាមគេញាក់ដោយកំលាំងលុយ ។

ហាំ : មិត្តទាំងប្អូន ពេលនេះថៅកែត្រូវការឯង គេថាអោយឯងម្នាក់ៗ ១ពាន់រៀលដល់គេផុតត្រូវការឯង គេអាចប្រើស្មៀតមួយកាច់ពី ឯងម្នាក់ជាង ១ពាន់រៀលវិញផង ពីព្រោះមនុស្សនេះ គ្មានជឿលើសេចក្ដីយុត្តិធម៌លើអំពើល្អខ្ពស់ទាបឡើយ ។

យ៉ាន : ឱ! ឱវាអើយ! ខ្ញុំទើបនឹងដឹងរឿង ថៅកែ យើងចិត្តចោរ ជាមនុស្សអាក្រក់ណាស់ ។

ថៅកែ : (និយាយតែម្នាក់ឯង) នៅទីបំផុត ខ្ញុំនៅតែម្នាក់ឯងទេដឹង ? ទេដូចនេះមិនកើតទេ អញយកលុយអញចាយទាំងអស់ អោយតែអញបានបក្សពួក គ្រាន់ធ្វើជាគ្នា កុំអោយចិត្តអញកំព្រាពេក។ (លឺ) អាមាន! អញអោយឯង ៣ពាន់ អាឯងថាដូចម្ដេច ?

មាន : ថៅកែ ...ថៅកែ ... ចុះអាសុខ ?

ហាំ : គេប្រើស្មៀតបំបែកគ្នាយើងហើយ ត្រូវយើងចងគ្នាជាបាច់វិញអោយបានទើបផ្ដួលពួកជិះជាន់មនុស្សបាន ។

សុខ : ណ្ហើយ លុយដែលថៅកែបំរុងអោយពួកខ្ញុំ ថៅកែវេរទៅអោយលោកបងផង់ចុះ ។

ហាំ : ទេអាសុខ អញមិនព្រមយកលុយនេះទៀតទេ អញសុខចិត្តអោយវង្ស ត្រកូលអញស្លាប់ចុះ ដើម្បីសេចក្ដីពិតផ្ទុះឡើង រួចទើបបានដឹងលឺគ្រប់ៗ គ្នាហើយ រកផ្លូវដោះស្រាយអោយបានឃើញ ។

ថៅកែ : អញក៏មិនខ្វីអោយ អាឯងដែរ លុយអញមាន អញសុខចិត្តដុតចោល ។

ជានីត : លោកអើយជួយស្ដាប់ ពីរោះណាស់ មានលុយស៊ូដុតចោល ត្រង់អ្នកក្រ មិនព្រមជួយ ។

ថៅកែ : (ចង់រត់ចេញ) នៅជជែកជាមួយអាអស់នេះ មិនបានជាការសោះ !...

ហាំ : ពួកយើងស្ទាក់ កុំអោយចេញរួច ហ៊ុមថៅកែ ចិត្តចោរនាយទុនទុច្ចរិត នេះអោយជាប់(ទាំងអស់គ្នា ធ្វើតាមកម្មករទាំងបួន ធ្វើដោយញញើត ញញើម) ។

ថៅកែ : ណ្ហើយ អា ៤ នាក់ អញនិយាយជាចុងបង្ហើយចុះ អាសុខ ១ ម៉ឺន អាទ្រី ១ ម៉ឺន អាគង់ ១ ម៉ឺន ។

មាន : ១ ម៉ឺនថៅកែហ៊ានអោយ ១ ម៉ឺន ?

ថៅកែ : អើ ! អញអោយ ១ ម៉ឺន ។

យ៉ាន : មានអើយ ! លុយបានដោយសំនូក ក្ដៅក្រហាយ មានឯងយកទៅក៏ទុក បានមិនយូរដែរ ។ លុយរកបានដោយងាយ ចាយក៏ដោយងាយប្រហែល ជាមានឯង យកទៅលេងល្បែងចាញ់អស់ផង មើលទៅ ចុះដល់អស់ លុយនោះទៅ មានឯងយ៉ាងដូចម្ដេចទៅទៀត ក្រៅពីនឹកស្ដាយថា អញ បានភរគេបានក្បត់មិត្ត អ្នកក្រដូចគ្នា ។ រំពឹងលើថៅកែ គេមិនមែនជួយ ឯងមួយជីវិតទេ គេមើលឃើញតែលុយនឹងគ្នា គេបីបួននាក់ប៉ុននោះ ។

គង់ : មែន ! ពួកយើងកុំចាញ់បោកថៅកែ កុំចាញ់បោកអាពួកនាយទុនមូលធន ដែលជាឈ្លើងជញ្ជក់ឈាម អារកយើងជិះជាន់យើង បឺតញើស បឺតឈាម

យើងគ្រប់ពេលវេលា ។ យើងត្រូវតែរួមគ្នាពួតដៃគ្នា ចងសាមគ្គីអោយស្អិតរមួត ហើយពុះពាររកសខ្មៅឱ្យទាល់តែឃើញ ។

ទ្រី : អាគង់និយាយត្រូវ ! ខ្ញុំមិនព្រមយកលុយ ១ម៉ឺនរបស់ចៅកែ ដើម្បីអោយមិត្តអ្នក ក្រដូចគ្នា ស្លាប់ដោយអយុត្តិធម៌ទេ ។

ជានីត : បងគង់ បង ទ្រីនិយាយត្រូវណាស់ ។ ខ្លួនខ្ញុំ ក៏សុំចូលដៃជាមួយនឹង ពួកបងៗដែរ ។ យើងទាំងអស់គ្នាតោងរួមដៃគ្នាចង្អុលមុខចោរ អោយចំចោរជាន់ខ្ពស់ ដែលចេះប្រើវិធី និងគ្រឿងរាប់មិនអស់ សំរាប់បំផ្លាញសង្គមខ្មែរ សង្គមមនុស្ស ។ ចោរបែបនេះ ខ្លាំងជាងចោរធម្មតា ដែលលួច ឬប្លន់ឯកជន ព្រោះចោរលួចប្លន់ហុតឈាមខ្មែរ គ្រប់គ្នា ដោយប្រើវិធី បន្លំបំបាត់ សូកប៉ាន់ និងអំពើអមនុស្សច្រើនទៀត ។
ចោរនេះ ជាចោរប្លន់ជាតិ ព្រោះចោរបែបនេះ មិនខ្លាចនឹងចូលដៃនឹងបរទេស លក់ជាតិខ្មែរ ដើម្បីខ្លួនបានចំណេញឡើយ ។

# ឆាកទី ៧

## ទាំងអស់គ្នាថែមពួកក្រុមនគរបាលចូលមក

សែហ្យ : អ្នកណាថា ឯណាចោរ ? យើងជាក្រុមនគរបាល ប្រាប់មុខចោរ យើងមក យើងចាប់ ។ (ទាំងអស់គ្នាជ្រួលភ័យ)

ភ្នាក់ងារទី ២ : កុំជ្រួលនៅអោយស្ងៀម !

ថៅកែ : អស់លោកមករកចាប់តែកុង ហំឬ ? នុ៎ះ វា ! ខ្ញុំជាថៅកែឡាន ឥលូវខ្ញុំប្តឹងថែមទៀត ព្រោះវាបានបំផ្លាញឡានខ្ញុំអោយខូចដែរ ។

ហំ : បាទ ! ខ្ញុំបាទនេះហើយ តែកុងហំ លោកចាប់ខ្ញុំចុះ ខ្ញុំមិនរត់ទេ ខ្ញុំព្រមទទួលថា បានប្រព្រឹត្តអំពើអមនុស្សធម៌មែន តែសូមលោកជ្រាបថា បើលោកចាប់ខ្ញុំ លោកត្រូវចាប់មនុស្សដែលបានណែនាំ ខ្ញុំអោយធ្វើអំពើឃោរឃៅនេះផង ។ មនុស្សនោះខ្ញុំ មិនបាច់ជំរាបលោកទេ ទុកអោយពួកទាំងអស់ គេជំរាបលោកជំនួសខ្ញុំចុះ ព្រោះខ្ញុំជាមនុស្សមានទោស ក្រែងលោកថា សំដីខ្ញុំ យកធ្វើការមិនកើត ។

ថៅកែ : (និយាយខ្សិបៗ) អាប្អូននាក់អញអោយ ពីរម៉ឺន ។

សែហ្យ : ទាំងអស់គ្នា តើមនុស្សណាមួយ ?

ផានីត : ថៅកែនេះឯង គាត់បានបញ្ចុះ ពូហំអោយបើកឡានបុកឡាន អុងប៉ាង ហុងលី ដោយសន្មតថា អោយពូហំ មួយម៉ឺនរៀល ។

ថៅកែ : អានេះ វាបង្កាច់ខ្ញុំទេលោក វាស្អប់ខ្ញុំ ព្រោះខ្ញុំមិន ព្រមអោយឡើងប្រាក់ខែ ។

យ៉ាន : លោកសែហ្យ ! រឿងថៅកែបញ្ចុះនេះជារឿងពិតពួកកម្មករឡានទាំងបួននាក់នេះ ជាសាក្សីស្រាប់ ព្រោះបានដឹងដែរ ។

ហាំ : អាមានជំរាបលោកដោយត្រង់ទៅ ។

ថៅកែ : អាមាន ...នៃ ...(ខ្សឹប) ពីរម៉ឺនរៀល ។

សែហ្វ : ម្តេចក៏នៅស្ងៀមទាំងអស់គ្នាហើយ ! មើលឆ្លើយប្រាប់ខ្ញុំ អោយត្រង់មកថា តើថៅកែនេះបាន ប្រើតែកុងអោយបុកឡាន គេមែន ឬ ទេ បើមែនថាមែន បើទេថាទេ (ចង្អុលទៅកម្មករទ្រី) មែនឬ អ្នក ឯណោះ ?

ថៅកែ : អាទ្រី

ហាំ : អាទ្រី

ទ្រី : មែន !

ថៅកែ : វាភរទេ ! វាភរទេ !

សែហ្វ : ចុះអ្នកនេះ ?

ថៅកែ : អាគង់អាណិតអញ !

ហាំ : អាគង់អាណិតខ្លួនអាឯង !

គង់ : មែន !

ថៅកែ : លោកសែហ្វ ! កុំជឿវា វាចូលដៃគ្នា សំលាប់ខ្ញុំហើយ ។

សែហ្វ : ចុះអ្នកឯណោះទៀត ?

មាន់ : មែន !

សុខ : មែន !

ថៅកែ : ឱពុទ្ធោអើយ !

សែហ្វ : អ្នកនេះជាប្រពន្ធតៃកុងហាំ ឬ ?

យ៉ាន : ចាស៎ លោក! ប្ដីខ្ញុំបានបុកឡានថៅកែ ហុងលី ព្រោះចង់បានលុយ ? ១ម៉ឺនអោយខ្ញុំ តាមសេចក្ដីសន្យារបស់ថៅកែដល់ប្ដីខ្ញុំ បានធ្វើអំពើនោះ ហើយថៅកែនេះមិនព្រមទាំងបើកលុយ ១ម៉ឺនរៀលនោះអោយប្ដីខ្ញុំផង ។

សែហ្វ : បាទ ! បាទខ្ញុំ យល់ហើយរឿងនេះ (ចង្អុលទៅជានីត) ចុះលោកប្អូនឯណោះយល់ដូចម្ដេចដែរ ។

ថៅកែ : ក្អួយជានីតជួយមាផង ។

ជានីត : ខ្ញុំ បានអោយយោបល់ហើយ តើឈ្មោះនេះឯង ដែលខ្ញុំស្រែក ចង្អុលថា ចោរនោះ ពេលដែលពួកលោកមកដល់ ។ (ថៅកែអួសដៃ មេនគរបាលទៅខ្សឹប) ។

សែហ្វ : តាងនាមក្រសួងនគរបាល ខ្ញុំសំរេចថា ត្រូវនាំខ្លួនឈ្មោះ ហំ ទៅក្រសួងនគរបាលជាតិទៅចូលចាប់ (ភ្នាក់ងារនគរបាល ក៏ប្រតិបត្តិតាម ។ ចាប់តែពូហំ) ។

ហំ : អរគុណ ហើយមិត្តទាំងអស់គ្នា ។ ម៉ែវាថែទាំកូន និងម្ដាយអោយបានស្រួលផង ។

ថៅកែ : ពួកអាឯងទាំងអស់គ្នា ឈប់ធ្វើការពីផ្ទះអញទៅ ទៅណាទៅចុះ ! ពួកអាក្រពើ !

សែហ្វ : ទៅ ! ទៅក្រសួងនគរបាល ។ (ច្រាន និងវាយពូហំ) ។

យ៉ាន : (ដោយស្រែកយំ) លោកអើយកុំធ្វើបាបប្ដីខ្ញុំ(រត់ចេញទៅ) ។

គង់ : ឱ ! អ្នកក្រអើយ ! តើខែណា ! ឆ្នាំណា ! សតវត្សណា ! ទើបបំរះរួចពីការជិះជាន់បែបនេះ ។ តើកាលណាទៅទើបមានយុត្តិធម៌ ។

សែហ្វ : ឈប់ ! ឈប់និយាយ (ប្រាប់នគរបាល) ចាប់វាភ្លាម ! នគរបាលចូលចាប់ពូគង់ចងទៀត ។

ផានីត : បញ្ហាស្រដៀងៗគ្នាបានចោទពេញទំហឹង នៅក្នុងសង្គមខ្មែរសព្វថ្ងៃ ដែលទើបនឹងរួចពី ការជិះជាន់របស់អាណានិគមការ គ្រាន់តែចាប់ ពួហាំ ទៅដាក់គុក មិនមែនដោះស្រាយ បញ្ហាទាំងនោះអោយបាន ស្រឡះទេ នាទីយើងឥលូវ គ្រាន់តែស្តែងឡើង អោយលោកអ្នកចាប់ អារម្មណ៍ លើបញ្ហាសង្គមខ្មែរខ្លះ អោយបានច្បាស់ផ្លូវត្រូវសំរាប់ដោះ ស្រាយ លោកទាំងអស់គ្នាជួយគិតចុះ នៅពេលដែលលោក អ្នកបាន មកឃើញ រឿងប្រឌិត លើរឿងពិតនៃបញ្ហាខ្លះ នៃសង្គមខ្មែរយើង រួចហើយនេះ ។

*ថ្ងៃទី ៩ ខែតុលា គ.ស. ១៩៥៦*

# ចូរថែទាំសៀវភៅរបស់អ្នក



សូមអ្នក :

១. ដាក់ក្របសៀវភៅរបស់អ្នកដោយថ្នាំស្អិត រឺក្រដាស ( ក្រដាសកាសែត រឺទស្សនាវដ្ដីក៏អាចប្រើបានដែរ ) ។

២. សំអាតដៃរបស់អ្នកអោយបានស្អាត មុនពេលចាប់កាន់ រឺបើកទំព័រសៀវភៅ ។

៣. នៅពេលប្រើប្រាស់សៀវភៅថ្មីជាលើកដំបូង សូមដាក់សៀវភៅផ្ដេកជាមុន រួចបើកមួយពីរបីទំព័រសិន ។ នៅពេលបើកទំព័រសៀវភៅ សូមសង្កេតមើលគល់សន្លឹកសៀវភៅផង ។ បើមានរបើក រឺរបេះចេញ សូមរកការបិទវាវិញយ៉ាងប្រុងប្រយ័ត្ន ។

៤. ប្រើក្រដាសមួយសន្លឹក ដើម្បីសៀតសំគាល់ទំព័រក្នុងសៀវភៅ ។

៥. បិទទំព័រសៀវភៅដែលរហែកអោយបានភ្លាមៗ ។

៦. កាន់សៀវភៅដោយប្រុងប្រយ័ត្ននៅពេលហុចពីមនុស្សម្នាក់ទៅម្នាក់ទៀត ។

៧. ទុកសៀវភៅកន្លែងស្ងួតស្អាតជានិច្ច ។

៨. នៅពេលអ្នកបាត់សៀវភៅ សូមជំរាបលោកគ្រូ អ្នកគ្រូភ្លាម ។



សូមអ្នក :

១. កុំបត់ទំព័រសៀវភៅ ។

២. កុំសរសេរនៅលើក្រប រឺទំព័រសៀវភៅ ។

៣. កុំកាត់រូបភាពចេញពីសៀវភៅ ។

៤. កុំហែក រឺផ្ដាច់ទំព័រណាមួយចេញពីសៀវភៅ ។

៥. កុំបើកចំហសៀវភៅ រឺផ្កាប់ទុកចោលនៅពេលមិនប្រើប្រាស់ ។

៦. កុំប្រើខ្មៅដៃ ប៊ិច រឺវត្ថុក្រាស់ៗ ទៅសៀតសំគាល់ទំព័រក្នុងសៀវភៅ ។

៧. កុំបង្ខំញាត់សៀវភៅទៅក្នុងសំពៀតដែលមានរបស់របរពេញហើយ ។

៨. កុំយកសៀវភៅទូលបាំងថ្ងៃ រឺភ្លៀង ។

៩. កុំអង្គុយលើសៀវភៅ ។

បោះពុម្ពផ្សាយឡើងវិញលើកទី ១
ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ
នៃក្រសួងអប់រំ យុវជន និងកីឡា
ព.ស ២៥៤៥ គ.ស ២០០១